សមាគមធនាគារនៅកម្ពុជា
THE ASSOCIATION OF BANKS IN CAMBODIA

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
Cambodia Microfinance Association

# សេចក្តីប្រកាសព័ត៌មាន

## កម្ពុជាដាក់ឱ្យប្រើប្រាស់ស្តង់ដាកិច្ចសន្យាឥណទាន និងខចែងស្តង់ដាកិច្ចសន្យាឥណទាន ដើម្បីពង្រឹងការការពារអតិថិជន និងតម្លាភាពវិស័យធនាគារ និងហិរញ្ញវត្ថុ

**ភ្នំពេញ, ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣៖** ស្តង់ដាកិច្ចសន្យាឥណទាន និងខចែងស្តង់ដាកិច្ចសន្យាឥណទានសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ដោយសមាគមធនាគារនៅកម្ពុជា (ABC) និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) កាលពីព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ នៅមណ្ឌលសិក្សាធនាគារនៃធនាគារជាតិនៃកម្ពុជា។

កម្មវិធីនេះរៀបចំឡើងក្រោមអធិបតីភាពលោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា លោក រ័ត្ន សោភ័ណ អនុប្រធានសមាគមធនាគារនៅកម្ពុជា លោក សុខ វឿន ប្រធានក្រុមប្រឹក្សាភិបាលសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា លោក ង៉ែត ចេក អគ្គនាយករង នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប.) អ្នកចូលរួមមកពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងភ្ញៀវកិត្តិយសមកពីស្ថាប័នពាក់ព័ន្ធផ្សេងទៀតប្រមាណ ៣០០ នាក់។

ស្តង់ដាកិច្ចសន្យាឥណទាន និងខចែងស្តង់ដាកិច្ចសន្យាឥណទាននេះ ធ្វើឡើងក្នុងគោលបំណងដើម្បីបង្កើនតម្លាភាព និងកិច្ចការពារអតិថិជន។ វិសាលភាពស្តង់ដាកិច្ចសន្យាឥណទាន និងខចែងស្តង់ដាកិច្ចសន្យាឥណទាននេះអនុវត្តចំពោះធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ គ្រឹះស្ថានឥណទានជនបទ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ។ ស្តង់ដាកិច្ចសន្យារឥណទាន និងខចែងស្តង់ដាកិច្ចសន្យាឥណទាន នឹងត្រូវអនុវត្តតែចំពោះការផ្តល់ឥណទានថ្មី ឬអតិថិជនថ្មី ហើយនឹងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣ នេះតទៅ។ ចំពោះទំហំប្រាក់កម្ចី/ឥណទានដែលមានទំហំតូចជាង ឬស្មើ ៥០.០០០ដុល្លារ (ប្រាំម៉ឺនដុល្លារអាមេរិក) គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់ តម្រូវឱ្យប្រើទម្រង់ និងលក្ខខណ្ឌដូចគ្នា នៃស្តង់ដាកិច្ចសន្យាឥណទាន ដែលចេញដោយសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ ស្តង់ដាកិច្ចសន្យាឥណទានដែលប្រើទម្រង់ និងលក្ខខណ្ឌដូចគ្នា ចែកចេញជាបួនប្រភេទរួមមាន៖ ១/. ស្តង់ដាកិច្ចសន្យាខ្ចីមានទ្រព្យធានា ២. ស្តង់ដាកិច្ចសន្យាខ្ចីគ្មានទ្រព្យធានា ៣/. កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុចលនវត្ថុ ៤/. ស្តង់ដាកិច្ចសន្យាឥណទានជាក្រុម។

ដោយឡែកចំពោះឥណទានធំជាង ៥០,០០០ដុល្លារ (ប្រាំម៉ឺនដុល្លារ) ដល់ ១០០,០០០ដុល្លារ (ដប់ម៉ឺនដុល្លារ) គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ ត្រូវដាក់បញ្ចូលខចែងស្តង់ដាកិច្ចសន្យាដែលចេញដោយសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ទៅក្នុងកិច្ចសន្យាឥណទានរបស់ខ្លួន។ ស្តង់ដានេះមិនអនុវត្តចំពោះឥណទានលើសពី ១០០,០០០ដុល្លារ (ដប់ម៉ឺនដុល្លារ) ឡើយ។

ស្តង់ដាកិច្ចសន្យាឥណទាន និងខចែងស្តង់ដាកិច្ចសន្យានេះត្រូវបានបង្កើតឡើងដោយសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដោយមានការគាំទ្រពីធនាគារជាតិនៃកម្ពុជា និងដោយមានការត្រួតពិនិត្យពីអ្នកច្បាប់ឯករាជ្យផងដែរ សំដៅលើកកម្ពស់តម្លាភាព និងកិច្ចការពារអ្នកប្រើប្រាស់ ព្រមទាំងរក្សាការប្រកួតប្រជែងដោយស្មើភាពនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។

ថ្លែងទៅកាន់អ្នកចូលរួមប្រមាណជាង ៣០០នាក់ក្នុងឱកាសដាក់ឱ្យប្រើប្រាស់ស្តង់ដាកិច្ចសន្យាឥណទាន និងខចែងស្តង់ដាកិច្ចសន្យាឥណទាននេះ លោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាបានកោតសរសើរ និងអបអរសាទរចំពោះក្រុមការងារធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងភាគីពាក់ព័ន្ធ ដែលបានសហការរៀបចំស្តង់ដាកិច្ចសន្យាឥណទាន និងខចែងស្តង់ដានៃកិច្ចសន្យាឥណទានសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនេះឡើង។ ការណ៍នេះគឺជា សមិទ្ធផលមួយថ្មីបន្ថែមទៀតក្នុងការចូលរួមចំណែកកិច្ចការពារអតិថិជន ក៏ដូចជាបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។

លោកជំទាវបណ្ឌិតអគ្គទេសាភិបាល បានបន្ថែមថា ស្តង់ដាកិច្ចសន្យាឥណទាន និងខចែងស្តង់ដានៃកិច្ចសន្យាឥណទានសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ គឺជាការចូលរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នៃនីតិកាលទី៧ របស់រាជរដ្ឋាភិបាល។

លោកជំទាវអគ្គទេសាភិបាលបានបញ្ជាក់ថា៖ «ខ្ញុំសូមលើកទឹកចិត្តដល់គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់ក្នុងការជំរុញ និងគាំទ្រដល់សេចក្តីណែនាំស្តីពីការអនុវត្តស្តង់ដាកិច្ចសន្យាឥណទាន និងខចែងស្តង់ដានៃកិច្ចសន្យាឥណទាន ដែលជាការបង្ហាញនូវការចូលរួមចំណែកជាមួយធនាគារជាតិនៃកម្ពុជា ក៏ដូចជារាជរដ្ឋាភិបាលក្នុងការងារគាំទ្រកិច្ចការពារអតិថិជន ក៏ដូចជាពង្រឹងបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈការផ្តល់សេវាប្រកបដោយការទទួលការទទួលខុសត្រូវ និងការប្រកួតប្រជែងប្រកបដោយក្រមសីលធម៌»។

លោក វ័ត្ន សោភ័ណ អនុប្រធានសមាគមធនាគារនៅកម្ពុជា បានមានប្រសាសន៍ថា ស្តង់ដាកិច្ចសន្យាឥណទានរួម និងខចែងស្តង់ដានៃកិច្ចសន្យាឥណទានសម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុនេះ ត្រូវបានបង្កើតឡើងដើម្បីជួយឱ្យសមាជិកទាំងអស់មានទម្រង់ស្តង់ដាកិច្ចសន្យារួម និង ខចែងស្តង់ដាកិច្ចសន្យាឥណទាន ដែលស្របតាមលក្ខខណ្ឌតម្រូវនៃប្រកាសស្តីពីខសន្យាមិនសុចរិត និង ស្មារតីនៃច្បាប់ស្តីពីការការពារអតិថិជន ។ លោកបន្តថា ស្តង់ដាកិច្ចសន្យាឥណទាន